ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
រដ្ឋបាលខេត្តកំពង់ធំ
លេខ ៖ ៣៦២ស.ជ.ណ

កំពង់ធំ, ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៤

# សេចក្តីជូនដំណឹង
# ស្តីពី
# ភាពមិនប្រក្រតីនៃការដេញថ្លៃគម្រោងមូលនិធិឃុំ-សង្កាត់ តាមបណ្តាក្រុង ស្រុកក្នុងខេត្តកំពង់ធំ

អភិបាលខេត្តកំពង់ធំ សូម ជម្រាបមក អ្នកទទួលការដែលបានចូលរួមដេញថ្លៃគម្រោងមូលនិធិឃុំ-សង្កាត់ថា ៖ កន្លងមកការដេញថ្លៃគម្រោងមូលនិធិឃុំ-សង្កាត់ នៅតាមបណ្តាក្រុង-ស្រុក ក្នុងខេត្តកំពង់ធំ មានដំណើរការល្អស្របតាមសៀវភៅណែនាំ ស្តីពីនីតិវិធីនៃការដេញថ្លៃគម្រោង (សៀវភៅ PIM) ប៉ុន្តែក្នុងឆ្នាំ ២០១៤ នេះ ក្រោយពីកាប្រកាសដេញថ្លៃគម្រោងឆ្នាំ ២០១៤ ពិនិត្យឃើញថាមានអ្នកទទួលការមួយចំនួនបានប្រព្រឹត្ត កំហុសធ្ងន់ និងបង្កឱ្យមានភាពអនាធិបតេយ្យ ក្នុងការដេញថ្លៃគម្រោងមូលនិធិឃុំ-សង្កាត់មួយចំនួនដោយ ទង្វើទាំងនេះចាត់ទុកថាជាការខ្វះខាត និងធ្វើឱ្យរាំងស្ទះដល់ដំណើរការអភិវឌ្ឍនៅថ្នាក់មូលដ្ឋាន។

ដើម្បីទប់ស្កាត់នូវបាតុភាពទាំងនេះអភិបាលខេត្ត សូមធ្វើការព្រមានចំពោះ អ្នកទទួលការមួយចំនួនបានប្រព្រឹត្តកំហុសធ្ងន់កន្លងមកដែលមានឈ្មោះដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. លោក | ខៀវ សុផានិត | ក្រុមហ៊ុន ខៀវ សុផានិត | ចុះបញ្ជីខេត្តកំពង់ចាម |
| ២. លោកស្រី | សេង ច័ន្ទដានី | ក្រុមហ៊ុន ខៀវ សុផានិត | ចុះបញ្ជីខេត្តកំពង់ចាម |
| ៣. លោក | យឹម សុខា | ក្រុមហ៊ុន យឹម សុខា | ចុះបញ្ជីខេត្តកំពង់ចាម |
| ៤. លោកស្រី | កាវ ស៊ីលីន | ក្រុមហ៊ុន កាវស៊ីលីន | ចុះបញ្ជីខេត្តកំពង់ឆ្នាំង |
| ៥. លោកស្រី | យែម សុខងឹម | ក្រុមហ៊ុន យែម សុខងឹម | ចុះបញ្ជីខេត្តព្រះវិហារ |
| ៦. លោក | ឱ សុផាន | ក្រុមហ៊ុន ឱ សុផាត | ចុះបញ្ជីខេត្តព្រះវិហារ |
| ៧. លោក | លី ម៉េងហាក់ | ក្រុមហ៊ុន លី ម៉េងហាក់ | ចុះបញ្ជីខេត្តព្រៃវែង |
| ៨. លោក | លី ងួនអេង | ក្រុមហ៊ុន លី ងួនអេង | ចុះបញ្ជីខេត្តព្រៃវែង |
| ៩. លោក | លី លីមហេង | ក្រុមហ៊ុន លី លីមហេង | ចុះបញ្ជីខេត្តព្រៃវែង |
| ១០. លោក | ឈឹន ដារិន | ក្រុមហ៊ុន ឈឹន ដារិន | ចុះបញ្ជីខេត្តក្រចេះ |
| ១១. លោក | គង់ វាសនា | ក្រុមហ៊ុន គង់ វាសនា | ចុះបញ្ជីខេត្តកំពង់ធំ |
| ១២. លោក | ជី យាន | ក្រុមហ៊ុន ជី យាន | ចុះបញ្ជីខេត្តកំពង់ធំ |
| ១៣. លោកស្រី | ឈិន ឈុំឈុនណា | ក្រុមហ៊ុន ឈុំឈុនណា | ចុះបញ្ជីខេត្តកំពង់ធំ |
| ១៤. លោក | លី ប៊ុនហេង | ក្រុមហ៊ុន លី ប៊ុនហេង | ចុះបញ្ជីខេត្តកំពង់ធំ |
| ១៥. លោក | ផេង ពាក | ក្រុមហ៊ុន ផេង ពាក | ចុះបញ្ជីខេត្តកំពង់ធំ |

| | | | |
|---|---|---|---|
| ១៦. លោក | សង ណាគី | ក្រុមហ៊ុន សង ណាគី | ចុះបញ្ជីខេត្តកំពង់ធំ |
| ១៧. លោក | តាន់ តេ | ក្រុមហ៊ុន តាន់ តេ | ចុះបញ្ជីខេត្តកំពង់ធំ |
| ១៨. លោក | ចុង គីមយន | ក្រុមហ៊ុន ចុង គីមយន | ចុះបញ្ជីខេត្តកំពង់ធំ |
| ១៩. លោក | វេង ប៊ុនធឿន | ក្រុមហ៊ុន វេង ប៊ុនធឿន | ចុះបញ្ជីខេត្តកំពង់ធំ |
| ២០. លោកស្រី | ហៃល គីមអ៊ុន | ក្រុមហ៊ុន ហៃល គីមអ៊ុន | ចុះបញ្ជីខេត្តកំពង់ធំ |
| ២១. លោក | ចក តុងហួរ | ក្រុមហ៊ុន វិរៈផល | ចុះបញ្ជីខេត្តកំពង់ធំ |

អ្នកទទួលការ (ក្រុមហ៊ុន) ទាំង ២១ ដែលបានរៀបរាប់ខាងលើបានប្រព្រឹត្តនូវកំហុសឆ្គងមានរូបភាពដូចខាងក្រោម ៖

- ឃុបឃិតដកសំណើដេញថ្លៃចេញ ដោយទុកសំណើដេញថ្លៃតិចជាងបី ដែលមិនអាចដំណើរការបាន
- ឃុបឃិតដកសំណើដេញថ្លៃចេញ ដោយទុកសំណើដេញថ្លៃចំនួនបី តែសំណើដេញថ្លៃនោះមិនមានលក្ខណៈជាតម្លៃប្រកួតប្រជែង
- បង្កបញ្ហាផ្សេងៗដែលនាំឱ្យរាំខានដល់ដំណើរការដេញថ្លៃ

អ្នកទទួលការទាំង ២១ រូប ត្រូវតែកែលម្អកំហុសឆ្គងខាងលើ និងអនុវត្តឱ្យបានត្រឹមត្រូវតាមនីតិវិធីសៀវភៅណែនាំ ស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ-សង្កាត់។ ក្នុងករណីមិនរាងចាលនៅតែប្រព្រឹត្តឱ្យមានកំហុសឆ្គងទៀត អ្នកទទួលការនោះនឹងត្រូវបានដកឈ្មោះចេញពីបញ្ជីឈ្មោះអ្នកទទួលការជារៀងរហូត។

ទទួលបានសេចក្តីជូនដំណឹងនេះ អ្នកទទួលការ និងភាគីពាក់ព័ន្ធទាំងអស់ ត្រូវចាត់ចែងអនុវត្តឱ្យត្រឹមត្រូវ ស្របតាមនីតិវិធី និងសេចក្តីណែនាំនានាដែលបានកំណត់ ដើម្បីបង្ហាញនូវតម្លាភាព គណនេយ្យភាពក្នុងកិច្ចដំណើរការដេញថ្លៃគម្រោងមូលនិធិឃុំ-សង្កាត់។

**អភិបាលខេត្ត**

អ៊ុត_សំអន

<u>ចម្លងជូន ៖</u>

- លេខាធិការដ្ឋាន គ.ជ.អ.ប
- ក្រុមប្រឹក្សាខេត្ត
  *"ដើម្បីជូនជ្រាប"*
- សាលាក្រុង-ស្រុកគ្រប់ស្រុក
  *"ដើម្បីសហការ និងអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ